#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia
+855 (0)77 374 110
www.sasabassac.com

# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃអង្គារ ទី ១២ ខែកក្កដា ឆ្នាំ ២០១១

## ស-សបាសាក់ សូមបង្ហាញជូននូវពិព័រណ៍សិល្បៈ *គ្មានចំណងជើង* ដោយ ខ្វៃ សំណាង



ខ្វៃ សំណាង, *គ្មានចំណងជើង*, ឆ្នាំ២០១១, រូបថត Digital C-Print

**ទីក្រុងភ្នំពេញ** – ស-សបាសាក់ មានសេចក្តីសោមនស្សរីករាយ សូមបង្ហាញជូនពិព័រណ៍សិល្បៈ *គ្មានចំណងជើង* ដោយ ខ្វៃ សំណាង។

គាត់បានឃើញមនុស្សកំពុងរុះរើផ្ទះមួយនៅលើទឹក។ គាត់បានសួរអ្នកទាំងនោះថាតើទឹកនេះជ្រៅដែរឬទេ។ ពួកគេបានឆ្លើយថា «ជ្រៅ»។ គាត់ក៏បានចាប់ផ្តើមចុះហែលក្នុងទឹក។ មនុស្សម្នាក់បានរំលឹកគាត់ថាទឹកនេះមិនស្អាតទេ។ គាត់បានហែលទៅរកបង្គោលឈើមួយ។ គាត់បានចងផ្អោបខ្លួនគាត់ទៅនឹងបង្គោលនោះ។ ខ្លួនរបស់គាត់បានជាប់ជាមួយនឹងចំណងខ្សែ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញគ្រួសារមួយកំពុងលីបំណែកផ្សេងៗនៃផ្ទះរបស់គេ។ គាត់បានហែលទៅកាន់បង្គោលឈើមួយ។ គាត់បានចងផ្អោបខ្លួនគាត់ទៅនឹងបង្គោលនោះ។ ខ្លួនរបស់គាត់បានជាប់ជាមួយនឹងចំណងខ្សែ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានទៅតំបន់មានទឹកមួយដែលមានផ្ទះជាច្រើន។ គាត់បានឃើញឈ្មោះនិងអាសយដ្ឋាននៅលើខ្លោងទ្វារផ្ទះ។ នៅពេលដែលគាត់ដើរចុះក្នុងទឹក គាត់សង្កេតឃើញមានប្រជាជនមើលមកកាន់គាត់។ មនុស្សម្នាក់បានសួរគាត់ថា តើគាត់ជាតួកុនកំពុងថតរឿងមែនទេ។ គាត់បានឆ្លើយថា «ខ្ញុំកំពុងបង្កើតស្នាដៃសិល្បៈ»។ នៅក្នុងទឹកនោះ គាត់បានរកឃើញសសរឈើមួយសំរាប់អង្គុយលើ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញសំរាមជាច្រើនអណ្តែតនៅលើទឹក។ គាត់បានចាប់ផ្តើមហែលនៅក្នុងទឹកដែលពោរពេញទៅដោយសំរាមនោះ ហើយស្វែងរកកន្លែងសុវត្ថិភាពមួយដែលគាត់អាចឈរបាន។ គាត់បានរកឃើញបន្ទះក្តារមួយនៅក្នុងទឹក ដែលគាត់អាចឈរលើបាន។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញផ្ទះជាច្រើនលិចទឹក។ គាត់បានជួលក្មេងប្រុសម្នាក់អោយជួយអុំទូកចម្លងគាត់ទៅកាន់ផ្ទះលិចទឹកមួយ។ គាត់បានចុះក្នុងទឹក ហើយស្វែងរកកន្លែងដែលអាចទ្រទម្ងន់របស់គាត់បាន។ គាត់បានរកឃើញធ្នើរមួយដែលជាប់នឹងបង្គោលឈើ។ គាត់បានឈរលើធ្នើរនោះ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញកន្លែងតូចមួយមានទឹក ដែលពីមុនធ្លាប់ជាតំបន់ដែលមានទឹកយ៉ាងធំ។ នៅឆ្ងាយបន្តិច គាត់បានឃើញមានខ្សាច់ និងគ្រឿងម៉ាស៊ីនមួយចំនួន។ គាត់បានដើរកាត់ព្រៃស្មៅ ហើយខ្លួនគាត់បានមត់បន្លា។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញរុក្ខជាតិដុះប្រជ្រៀតគ្នានៅលើទឹក។ នៅឆ្ងាយបន្តិច គាត់បានឃើញមានអាគារមួយចំនួន។ ប្រជាជនបានប្រាប់គាត់ថា «ទឹកនេះជ្រៅណាស់»។ ពួកគេបានប្រាប់គាត់ទៀតថា «ផ្ទះល្វែងទាំងនោះភាគច្រើនគ្មានមនុស្សនៅទេ»។ គាត់បានរកឃើញឈើពីរកំណាត់ ហើយក៏ដាក់វានៅពីលើរុក្ខជាតិនោះ។ គាត់បានឈរពីលើកំណាត់ឈើនោះ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញរុក្ខជាតិដុះជាជួរនៅលើទឹក។ នៅឆ្ងាយបន្តិច គាត់បានឃើញមានខ្សាច់។ គាត់បានដើរចុះទៅក្នុងទឹករាក់នោះ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

គាត់បានឃើញខ្សាច់ ដែលពីមុនជាកន្លែងមានទឹក។ គាត់បានដើរនៅលើខ្សាច់ រួចឆ្លងកាត់ស្មៅ។ គាត់បានចាក់ខ្សាច់មួយធុងទៅលើក្បាលគាត់។

**អំពីសិល្បករ៖**
ខ្វៃ សំណាង ឆ្លុះបញ្ចាំងអំពីទិដ្ឋភាពផ្សេងៗនៅក្នុងសង្គមកម្ពុជា ដើម្បីចោទជាសំណួរស្តីពីផលប៉ះពាល់និងទំនាក់ទំនងរបស់បញ្ហាទាំងនោះនៅក្នុងពេលបច្ចុប្បន្ន ប្រកបដោយភាពល្អិតល្អន់ និងកំប្លុកកំប្លែង។ សំណាង (កើតនៅខេត្រស្វាយរៀង ក្នុងឆ្នាំ១៩៨២) បានទទួលបរិញ្ញាបត្រផ្នែកវិចិត្រសិល្បៈ ជំនាញវិចិត្រកម្ម ពីសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៅទីក្រុងភ្នំពេញ ឆ្នាំ ២០០៦។ ស្នាដៃរបស់គាត់ត្រូវបានដាក់តាំងយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា ហើយពិព័រណ៍អន្តរជាតិរបស់គាត់រួមមាន *រាត្រីប្រចាំឆ្នាំនៃមហោស្រពរូបថត Arles* ប្រទេសបារាំង (២០០៨, ២០១១) *តាំងពីមុនមកទល់បច្ចុប្បន្ន* នៅវិចិត្រសាល 10 Chancery Lane ទីក្រុងហុងកុង (២០០៩) *តូក្យូ ២០១០* នៅ Tokyo Wonder Site Hongo (២០១១)។ សំណាងគឺជាសិល្បករបានស្នាក់នៅ Tokyo Wonder Site Aoyama (២០១០)។

**អំពីស-សបាសាក់៖**
ស-សបាសាក់ គឺជាវិចិត្រសាល និងមណ្ឌលធនធានមួយ ដែលប្តេជ្ញាក្នុងការបង្កើត សម្របសម្រួល និងចែករំលែកវប្បធម៌ទស្សសិល្បៈសហសម័យនៅក្នុងនិងចេញពីប្រទេសកម្ពុជា។

**ព័ត៌មានលំអិតអំពីពិព័រណ៍៖**

| | |
|---|---|
| ពិព័រណ៍៖ | *គ្មានចំណងជើង* ដោយ ខ្វៃ សំណាង |
| បើកសម្ពោធ៖ | ថ្ងៃសុក្រ ទី ១៥ កក្កដា ម៉ោង ៦:០០ - ៨:០០ យប់ |
| កាលបរិច្ឆេទ៖ | ១៥ កក្កដា - ២១ សីហា ២០១១ |
| ម៉ោងទស្សនា៖ | ថ្ងៃព្រហស្បតិ៍ និងសុក្រ ម៉ោង ២-៦ ល្ងាច ថ្ងៃសៅរ៍ និងអាទិត្យ ម៉ោង ១០ ព្រឹក - ៦ ល្ងាច |
| ទីតាំង៖ | ស-សបាសាក់ នៅផ្ទះលេខ ១៨ ជាន់ទី២ មហាវិថីសុធារស ភ្នំពេញ |
| គេហទំព័រ៖ | www.sasabassac.com |

**ទំនាក់ទំនង៖**
អេរីន ឃ្លីសុន, សហស្ថាបនិក / អ្នករៀបចំពិព័រណ៍សិល្បៈ / នាយក
ទូរសព្ទ័ +៨៥៥ (០)១២ ៥០៧ ៩១៧, អ៊ីមែល erin@sasabassac.com